# គណៈកម្មាធិការគ្រប់គ្រងល្បែងភ្នាល់រដ្ឋកាលីហ្វ័រនីញ៉ា
# ដំណើរការបែបបទរបស់រដ្ឋ - អ្វីដែលត្រូវធ្វើ

គណៈកម្មាធិការគ្រប់គ្រងល្បែងភ្នាល់រដ្ឋកាលីហ្វ័រនីញ៉ា (គណៈកម្មាធិការ) និង នាយកដ្ឋានយុត្តិធម៌រដ្ឋកាលីហ្វ័រនីញ៉ា, ការិយាល័យគ្រប់គ្រងល្បែងភ្នាល់ (ការិយាល័យ) ជាផ្នែករៀបចំបទបញ្ញត្តិក្នុងឧស្សាហកម្មបនល្បែងក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

ក្នុងនាមជាផ្នែកនៃរចនាសម្ព័ន្ធនេះ, ការិយាល័យបានទទួលបែបបទស្នើសុំអជ្ញាប័ណ្ណ, ដំណើរការស៊ើបអង្កេតប្រវត្តិ របស់បេក្ខភាព និង ផ្តល់ជូននូវការណែនាំទៅកាន់ គណៈកម្មាធិការ អំពីភាពសមស្របរបស់បេក្ខភាព ។

បុគ្គលិករបស់ គណៈកម្មាធិការ បានត្រួតពិនិត្យរបាយការណ៍ស៊ើបអង្កេតប្រវត្តិរូប របស់ការិយាល័យ និង បញ្ជូនទៅកាន់គណៈកម្មាធិការនូវសេចក្តីណែនាំ ។ ហើយគណៈកម្មាធិការបានធ្វើការពិចារណារៀបចំវេទិការដេញដោលជាសាធារណៈ ចំនួនពីរដងក្នុងមួយខែ ។ ទាំងនេះជាចំនុចមួយចំនួនដែលលោកអ្នកត្រូវចងចាំពេលដែលដំណើរការរៀបចំបែបបទ ៖

- ធ្វើការត្រួតពិនិត្យនូវបែបបទរបស់អ្នក អោយបានម៉ត់ចត់ និង បានសព្វគ្រប់។ សមត្ថភាពរបស់បេក្ខភាពក្នុងការភ្ជាប់មកនូវប្រវត្តិរូបអោយបានច្បាស់លាស់គឺ មានសារសំខាន់ខ្លាំងណាស់ នៅពេលដែល គណៈកម្មាធិការពិចារណានូវភាពសុចរិតភាព និង ភាពស្មោះត្រង់។ ប្រសិនបើអ្នកមិនប្រាកដថាអ្នកគួរភ្ជាប់មកនូវឯកសារអ្វីមកជាមួយ ជាការល្អដែលអ្នកគួរភ្ជាប់ឯកសារទាំងអស់ដែលលោកអ្នកមាន ប្រសើរជាងមិនបានភ្ជាប់ ។ ឯកសារបានសព្វគ្រប់ និង មានភាពម៉ត់ចត់ជាទំនួលខុសត្រូវរបស់បេក្ខភាព ។
- ការបញ្ជូនបែបបទមកទាន់ពេលវេលា ។ មានច្បាប់ និង បញ្ញត្តិដែលតម្រូវអោយបេក្ខភាពបញ្ជូនបែបបទក្នុងកាលកំណត់មួយ ។ បេក្ខភាពគួរអនុញ្ញាតិអោយខ្លួនឯងមានពេលវេលាគ្រប់គ្រាន់ ដើម្បីធានាថាអាចបំពេញបែបបទបាន ហើយផ្ទៀងផ្ទាត់វា អោយបានម៉ត់ចត់ និង គ្រប់គ្រាន់ ព្រមទាំងសួរសំណួរតាមតម្រូវការ ។ កាលកំណត់ជាទំនួលខុសត្រូវរបស់បេក្ខភាពផងដែរ ។
- ការភ្ជាប់មកឱ្យបានមុននូវលិខិតថ្កោលទោស ។ ទាំងនោះ **រាប់បញ្ចូល** ទាំងទោសណាដែលត្រូវបានលើកលែង និង/ឬ លុបចោល, លុះត្រាតែត្រូវបានបោះត្រាដោយបញ្ជាតុលាការ។ សូមពិនិត្យចំពោះការបំពានច្បាប់ចរាចរណ៍។ ប័ណ្ណផាកពិន័យចរាចរណ៍មិនត្រឹមតែជាលទ្ធផលនៃការប្រព្រឹត្តិបទល្មើសនោះទេ ប៉ុន្តែក៏ជាបទល្មើសមជ្ឈឹម ឬ ការថ្កោលទោសបទឧក្រិដ្ឋផងដែរ ។ ការថ្កោលទោសបទល្មើសមជ្ឈឹម និង បទឧក្រិដ្ឋ ទោះបីជាការល្មើសចរាចរណ៍ ត្រូវតែភ្ជាប់ឯកសារមកជាមួយបែបបទរបស់អ្នក ។
- ការភ្ជាប់មកជាមួយនូវការវិវឌ្ឍន៍ពេលដែលបានបែកចេញពីការជួលជាបុគ្គលិក។ ប្រសិនបើលោកអ្នកបានបណ្តេញ ឬ លាលែងពីតំណែង សូមប្រាប់អោយយើងបានដឹង និង បកស្រាយនូវការវិវឌ្ឍន៍។ ការបកស្រាយថា "បញ្ហាផ្ទាល់ខ្លួន - Personal" មិនមែនជាហេតុផលនោះទេ ។
- ការភ្ជាប់មកនូវឯកសារកម្មសិទ្ធិលំនៅដ្ឋាន។ យើងខ្ញុំបានយល់ថា ហេតុអ្វីបានជាបេក្ខភាពមិនចង់ចែករំលែកនូវព័ត៌មាននេះ ។ ប៉ុន្តែវាមានការសំខាន់ដែលភ្ជាប់ឯកសារកម្មសិទ្ធិ **ទាំងអស់** តាមការស្នើសុំព័ត៌មាន ។
- ដោះស្រាយបញ្ហាព្រហ្មទណ្ឌ និង រដ្ឋប្បវេណីដែលមិនទាន់ដោះស្រាយ ។ ត្រូវតែសកម្មក្នុងការដោះស្រាយបញ្ហាដែលជាប់គាំងនៅតុលាការ រួមទាំងប្រាក់ដែលជំពាក់ទាំងឡាយ និង **ឯកសារគ្រប់យ៉ាង**។ អ្នកនឹងត្រូវបានសាកសួរអោយផ្តល់នូវឯកសារដែលទាក់ទិននឹងបញ្ហាទាំងនេះ។
- ការចូលរួម។ ប្រសិនបើគណៈកម្មាធិការបានជម្រាបអ្នកថា សមាជិកគណៈកម្មការចង់កោះអញ្ជើញអ្នកដើម្បីប្រជុំ នោះមានន័យថាជារឿងសំខាន់បំផុត ដែលតម្រូវអោយអ្នកចូលរួម។ ប្រសិនបើអ្នកមិនអាចចូលរួម សូមប្រាប់អោយបុគ្គលិកដឹងជាបន្ទាន់ ដូច្នេះអ្នកនឹងត្រូវបានរៀបចំការណាត់សារជាថ្មីម្តងទៀត។ បើពុំនោះទៀតសោត ការបន្តសុពលភាពមិនត្រូវបានធានានោះទេ។ **ការសម្រេចបន្តសុពលភាពអជ្ញាប័ណ្ណជា ឯកសិទ្ធិពិសេស មិនមែនជាសិទ្ធិទូទៅទេ។**

## ការកំណត់សំខាន់

បេក្ខភាពត្រូវតែបញ្ជូនបែបបទរបស់ពួកគេទៅកាន់ការិយាល័យគ្រប់គ្រងល្បែងភ្នាល់តាមកាលកំណត់ដូចខាងក្រោម ៖

**ប្រភេទ អជ្ញាប័ណ្ណ បុគ្គលិករបស់បន្ទប់ល្បែង (ប័ណ្ណអនុញ្ញាតិការងារ / បុគ្គលិកគោល)**

- បណ្តោះអាសន្ន/ដំបូង — មុនពេលសន្មតថាកាន់តួនាទី
- បន្តសុពលភាព — 120 ថ្ងៃមុនពេលផុតសុពលភាព

**ប្រភេទអជ្ញាប័ណ្ណបុគ្គលិកភាគីទីបីដែលស្នើសុំផ្តល់សេវាកម្មអ្នកលេងល្បែង (អ្នកធ្វើការ/អ្នកមើលការខុសត្រូវ)**

- បណ្តោះអាសន្ន/ដំបូង — មុនពេលសន្មតថាកាន់តួនាទី
- បន្តសុពលភាព — 120 ថ្ងៃមុនពេលផុតសុពលភាព

**អត្ថប្រយោជន៍របស់ម្ចាស់**

- ឯកសារដែលអាចរកបាន និងបែបបទត្រូវតែបានទទួល និងអនុម័តដោយគណៈកម្មាធិការ, ជាមុន ចាត់ទុកថាត្រូវតាមច្បាប់
- បន្តសុពលភាព — 120 ថ្ងៃមុនពេលផុតសុពលភាព


អាសយដ្ឋាន 2399 Gateway Oaks Drive, Suite 220
Sacramento, CA 95833
ទូរស័ព្ទ: 916-263-0700
សារអេឡិចត្រូនិក cgcc.ca.gov
សារអេឡិចត្រូនិច comments@cgcc.ca.gov


កំណែ ខែឧសភា ឆ្នាំ2021